**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH WATER SUPPLY AUTHORITY

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
**"រ.ទ.ស.ភ"**
លេខ .១៦០.ស.ស.ណា

# សេចក្តីជូនដំណឹង
## ស្តីពី កិច្ចប្រជុំក្រុមប្រឹក្សាភិបាល អាណត្តិទី៥ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនជ្រាបថា នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៥ វេលាម៉ោង ០៨:៣០នាទីព្រឹក រ.ទ.ស.ភ នឹងរៀបចំកិច្ចប្រជុំសាមញ្ញ លើកទី១៧ របស់ក្រុម-ប្រឹក្សាភិបាល អាណត្តិទី៥ នៃ រ.ទ.ស.ភ នៅទីចាត់ការប្រតិបត្តិនៃ រ.ទ.ស.ភ ដែលមានរបៀបវារៈដូចខាងក្រោម៖

១. របាយការណ៍ស្តីពីលទ្ធផលការងារសវនកម្មផ្ទៃក្នុង ត្រីមាសទី៣ ឆ្នាំ២០១៥
២. របាយការណ៍លទ្ធផលកិច្ចលទ្ធកម្មអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ និងសំណើសុំ ពិនិត្យ-អនុម័ត លើគម្រោងកិច្ចលទ្ធកម្ម ឆ្នាំ២០១៦
៣. របាយការណ៍ស្តីពីការប្រើប្រាស់មូលនិធិបម្រើផលប្រយោជន៍សង្គមអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៥ និងសំណើសុំ ពិនិត្យ-អនុម័ត លើគម្រោងប្រើប្រាស់មូលនិធិសង្គមឆ្នាំ២០១៦
៤. របាយការណ៍លទ្ធផលការងារឆ្នាំ២០១៥ (៨ខែបូក៤ខែប៉ាន់ស្មាន) និងសំណើសុំ ពិនិត្យ-អនុម័ត លើគម្រោងផែនការឆ្នាំ២០១៦
៥. សំណើសុំគោលការណ៍អនុញ្ញាតទិញដីសាងសង់រោងចក្រផលិតទឹកស្អាតថ្មី
៦. សំណើសុំគោលការណ៍ដើម្បីខ្ចីឥណទាន សម្រាប់សាងសង់រោងចក្រ និងប្រព័ន្ធបណ្តាញទឹកមេ
៧. សំណើសុំរុះរើសំណង់រោងចក្រចំការមនចាស់ ដើម្បីសាងសង់រោងចក្រចំការមនថ្មី សមត្ថភាពផលិត ៦០.០០០ម$^{៣}$/ថ្ងៃ
៨. សំណើសុំ ពិនិត្យ-សម្រេច លើបំណុលនៃការទិញភាគហ៊ុន រ.ទ.ស.ភ របស់មន្ត្រី-និយោជិត រ.ទ.ស.ភ
៩. សំណើសុំ ពិនិត្យ-សម្រេច លើអាណត្តិរបស់ អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន និងអភិបាលឯករាជ្យ ជាសមាជិកក្រុមប្រឹក្សាភិបាលនៃ រ.ទ.ស.ភ
១០. ផ្សេងៗ
  - ក/- សំណើសុំក្រុមប្រឹក្សាភិបាលឯកភាពជាគោលការណ៍ ក្នុងការទិញបំពង់ទំហំ ១៦០០ ម.ម និងសម្ភារតភ្ជាប់ដែលសល់ពីការអនុវត្តគម្រោងសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ ជំហានទី១ ពីក្រុមហ៊ុន Moya Asia
  - ខ/- របាយការណ៍ស្តីពីការអនុវត្តអាករលើតម្លៃបន្ថែម (VAT) ក្នុងគម្រោងហិរញ្ញប្បទានបរទេស និងសំណើសុំគោលការណ៍ឯកភាពឱ្យ រ.ទ.ស.ភ សុំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួច VAT រាល់ការផ្គត់ផ្គង់ទំនិញ និងសេវាក្នុងស្រុក

អាស្រ័យហេតុនេះ សូមវិនិយោគិន និងសាធារណជនជ្រាប។

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០១៥
**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ទីស្នាក់ការ : លេខ ៤៥ ផ្លូវ ១០៦ សង្កាត់ ស្រះចក ខណ្ឌ ដូនពេញ, ទូរស័ព្ទ: ០២៣-៧២៤-០៤៦ Email: admin@ppwsa.com.kh